

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋបាលជលផល

# កម្មវិធីជំរុញកំណើនវិស័យជលផលកម្ពុជា ប្រកបដោយចីរភាព និងបរិយាប័ន្ន ផ្នែកនេសាទ

( CAPFISH-Capture )

## របាយការណ៍ស្ថិតិស្តីពី

## ការវាយតម្លៃផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជា

ប្រចាំត្រីមាស (កក្កដា-កញ្ញា) ឆ្នាំ២០២១

ចងក្រងដោយ៖ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

ឧបត្ថម្ភគាំទ្រដោយ៖ សហភាពអឺរ៉ុប
ACA/២០១៨/០៤១-៤៦៦ និង ACA/២០១៩/០៤១-៥៩៤





## ១.សេចក្តីផ្តើម

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលផលទឹកសាប (IFReDI) ក្រោមជំនួយបច្ចេកទេសកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ននៃអង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិ (FAO CAPFISH) ក្រោមការគាំទ្រថវិការបស់សហភាពអឺរ៉ុប (EU) កំពុងអនុវត្តការវាយតម្លៃផលនេសាទទឹកសាបតាមបែបវិទ្យាសាស្ត្រដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍តាមបែបរំលឹកឡើងវិញ អំពីផលនេសាទរយៈពេល៥ថ្ងៃ ជារៀងរាល់ខែដោយគ្របដណ្តប់គ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា។ គោលបំណងនៃការវាយតម្លៃនេះ គឺដើម្បីទទួលបានព័ត៌មានកាន់តែប្រសើរអំពីផលនេសាទ និងសមត្ថភាពនៃការនេសាទរបស់គ្រួសារអ្នកនេសាទខ្នាតតូចក្នុងប្រទេសកម្ពុជា និងបង្កើតវិធីសាស្ត្រតាមដានផលនេសាទ និងដើម្បីនិរន្តរភាពនៃការអនុវត្តការវាយតម្លៃផលនេសាទទឹកសាប ក្រោមការគាំទ្របច្ចេកទេសដោយ IFReDI ដល់ខណ្ឌរដ្ឋបាលជលផលថ្នាក់ខេត្តអនុវត្តនាថ្ងៃអនាគត។

ការចុះប្រមូលទិន្នន័យដែលបានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ២០២១ គឺជាផ្នែកមួយនៃការបណ្តុះបណ្តាដោយផ្ទាល់ផងដែរដល់ក្រុមការងារប្រមូលទិន្នន័យរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប និងមន្ត្រីខណ្ឌរដ្ឋបាលជលផល។ បន្ទាប់មក ការប្រមូលទិន្នន័យបានបន្តគ្របដណ្តប់លើគ្រួសារអ្នកនេសាទនៅតាមខេត្តគោលដៅជាបន្តបន្ទាប់។

## ២. វិធីសាស្ត្រនៃការប្រមូលនិងវិភាគទិន្នន័យ

ការពិពណ៌នាអំពីវិធីសាស្ត្រនៃការប្រមូល និងវិភាគទិន្នន័យផលនេសាទទឹកសាបអាចរកបានតាមរយៈ រដ្ឋបាលជលផល (FiA) ឆ្នាំ២០២១៖ ឯកសារណែនាំការវាយតម្លៃផលនេសាទទឹកសាបតាមបែបវិទ្យាសាស្ត្រក្នុងប្រទេសកម្ពុជា ដោយប្រើការសម្ភាសន៍តាមបែបរំលឹកឡើងវិញ ចងក្រងដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៤៧ទំព័រ។





របាយការណ៍ស្ថិតិត្រីមាសនេះ គឺជារបាយការណ៍បូកសរុបលទ្ធផលចេញពីរបាយការណ៍ស្ថិតិខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ២០២១។

## ៣. លទ្ធផល

សរុបជារួមការប្រមូលទិន្នន័យ នៅកំឡុងខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២១ ដូចបានបង្ហាញនៅក្នុងតារាងទី១ បានកើនឡើងជាបន្តបន្ទាប់ ពោលការសម្ភាសន៍សំណាកគ្រួសារគោលដៅបានកើនពី ២៤,៤% នៅខែកក្កដា ទៅ៤៩,៩% នៅខែកញ្ញា ឆ្នាំ២០២១។



**តារាងទី១.** ចំនួនគ្រួសារអ្នកនេសាទ ដែលបានជ្រើសរើសដោយចៃដន្យសម្រាប់ការសម្ភាសន៍ និងសមាមាត្រនៃគ្រួសារអ្នកនេសាទគោលដៅតាមតំបន់នេសាទសម្រាប់ ខែកក្កដា-កញ្ញា ឆ្នាំ២០២១

| តំបន់នេសាទ | ភូមិ | | | | គ្រួសារអ្នកនេសាទ | | | |
|---|---|---|---|---|---|---|---|---|
| | កក្កដា | សីហា | កញ្ញា | ទិសដៅ | កក្កដា | សីហា | កញ្ញា | ទិសដៅ |
| ឆ្នេរ | - | - | - | ៤ | - | - | - | ៦០ |
| វាលទំនាបលិចទឹក | ៤ | ១២ | ១២ | ២១ | ៥៨ | ១៦៨ | ១៨១ | ៣១៥ |
| ភ្នំ | - | ១ | ២ | ៧ | - | ១២ | ២៤ | ១០៥ |
| ខ្ពង់រាប | ៣ | ៦ | ៦ | ៧ | ២៤ | ១២៦ | ៩០ | ១០៥ |
| ទន្លេសាប | ៨ | ១១ | ១១ | ២១ | ១៣៨ | ១២៨ | ១៥៤ | ៣១៥ |
| **សរុប** | **១៥** | **៣០** | **៣១** | **៦០** | **២២០** | **៤៣៤** | **៤៤៩** | **៩០០** |
| | **២៥,០%** | **៥០,០%** | **៥១,៧%** | | **២៤,៤%** | **៤៨,២%** | **៤៩,៩%** | |

ដោយមើលឃើញពីស្ថានភាពនៃការចុះជ្រើសរើសគ្រួសារអ្នកនេសាទនៅតាមភូមិគោលដៅ សម្រាប់ធ្វើការសម្ភាសន៍ប្រមូលទិន្នន័យផលនេសាទប្រចាំខែមិនអាចគ្របដណ្តប់ក្នុងខែសីហា ដល់ខែកញ្ញា រដ្ឋបាលជលផលបានសម្រេចចិត្តគៀងគរមន្ត្រីសម្រាប់ការអនុវត្តប្រមូលទិន្នន័យបន្ថែម នៅខែតុលា ដោយផ្តោតការពង្រីកការគ្របដណ្តប់លើភូមិ និងគ្រួសារអ្នកនេសាទគោលដៅទាំងអស់។

ចំនួនសំណាកដែលបានគ្របដណ្តប់មានតិច ក្នុងកំឡុងខែកក្កដា ឆ្នាំ២០២១ គឺបាននាំអោយមានកង្វះភាពត្រឹមត្រូវតាមលក្ខណៈស្ថិតិ (ភាពជាក់លាក់) ដល់ការប៉ាន់ប្រមាណលនេសាទប្រចាំថ្ងៃ និងផលនេសាទសរុបសម្រាប់តំបន់ទំនាបលិចទឹក និងទន្លេសាប (តារាងទី២ និងតារាងទី៣)។ ការប៉ាន់ប្រមាណសមត្ថភាពចាប់ក្នុងមួយខ្នាតឯកតា (CPUE) ជាមធ្យមប្រចាំថ្ងៃតាមគ្រួសារអ្នកនេសាទ និងការប៉ាន់ប្រមាណផលនេសាទសរុប មានកម្រិតលំអៀងទាបជាង ២០%។

ផលនេសាទតាមគ្រួសារអ្នកនេសាទប្រចាំថ្ងៃ នៅតំបន់វាលទំនាបលិចទឹក និងតំបន់ខ្ពង់រាប គឺមានចំនួនប្រហាក់ប្រហែលគ្នា ពោលគឺនេសាទបានតិចជាង ២គ.ក្រ/គ្រួសារ/ថ្ងៃ ខណៈដែលផលនេសាទប្រចាំថ្ងៃតាមគ្រួសារអ្នកនេសាទនៅតំបន់ទន្លេសាប មានចំនួនច្រើនជាងពីរដង។ ដោយឡែកផលនេសាទប្រចាំថ្ងៃសម្រាប់គ្រួសារអ្នកនេសាទនីមួយៗនៅតំបន់ភ្នំមិនទាន់អាចវាយតម្លៃបាននៅឡើយ។

**តារាងទី២.** ផលនេសាទតាមគ្រួសារអ្នកនេសាទ **ប្រចាំថ្ងៃគិត**ជាមធ្យម (CPUE) ពណ៌ក្រហមបង្ហាញថា ផលនេសាទក្នុងមួយខ្នាតឯកតា មានកម្រិតលម្អៀង ធំជាង ២០% ( relative standard error)

| តំបន់នេសាទ | % គ្រួសារអ្នកនេសាទសកម្ម | | | ផលនេសាទប្រចាំថ្ងៃតាមគ្រួសារអ្នកនេសាទ (គ.ក្រ) | | |
|---|---|---|---|---|---|---|
| | កក្កដា | សីហា | កញ្ញា | កក្កដា | សីហា | កញ្ញា |
| ឆ្នេរ | - | - | - | - | - | - |



| | | | | | | |
|---|---|---|---|---|---|---|
| ទំនាបលិចទឹក | ២៧,៦% | ១៩,០% | ២៩,៨% | ២,៩៦ | ១,៨១ | ១,៥៥ |
| ភ្នំ | - | ២៥,០% | ២៩,២% | | ០,៥៣ | ១,៩០ |
| ខ្ពង់រាប | ៦៦,៧% | ៥៤.០% | ៤៨,៩% | ១,៣១ | ១,៧៥ | ១,៩៤ |
| ទន្លេសាប | ៤០,៦% | ៤៨,៤% | ៦៥,៦% | ៥,០០ | ៣,១៧ | ៣,៥៨ |
| **សរុប** | **៤០,០%** | **៣៨,០%** | **៤៥,៩%** | **៣,៩៩** | **២,២៧** | **២,៦៤** |

កម្រិតលម្អៀង (Relative standard error) មានកម្រិតខ្ពស់ (តារាងទី៣) គឺបណ្ដាលមកពីមានការប្រែប្រួលខ្លាំងនៃផលនេសាទ និងចំនួនសំណាកមិនទាន់គ្របដណ្ដប់បានពេញលេញនៅតំបន់វាលទំនាបលិចទឹក និងតំបន់ទន្លេសាប។ ដូចនេះការប៉ាន់ប្រមាណផលនេសាទសរុបសម្រាប់ខែកក្កដា ឆ្នាំ២០២១ មិនទាន់ផ្ដល់ភាពជឿជាក់បាននៅឡើយ។ សម្រាប់ខែសីហា និងខែកញ្ញា គឺអាចផ្ដល់នូវភាពជឿជាក់បាន លើកលែងតែការប៉ាន់ប្រមាណសម្រាប់តំបន់នេសាទនៅតំបន់ភ្នំ និងខ្ពង់រាបប៉ុណ្ណោះ ដោយហេតុថាផលនេសាទសរុបនៃតំបន់ទាំងពីរនេះរួមចំណែក ប្រមាណតែ ៥% នៃផលនេសាទសរុប។ តម្លៃនៃភាពលម្អៀង (relative standard error) បង្ហាញថា ការប្រែប្រួលនៃផលនេសាទ អាចតម្រូវឱ្យមានការបង្កើនទំហំសំណាកនៃគ្រួសារអ្នកនេសាទ។

**តារាងទី៣.** ផលនេសាទប៉ាន់ប្រមាណសរុប តាមតំបន់នេសាទ ពណ៌ក្រហមបង្ហាញពីការប៉ាន់ប្រមាណ ដែលមានកម្រិតលម្អៀងធំជាង ២០% (relative standard error)។

| តំបន់នេសាទ | កក្កដា | | សីហា | | កញ្ញា | | សមាមាត្រផលនេសាទ |
|---|---|---|---|---|---|---|---|
| | ផលនេសាទ (តោន) | ε% | ផលនេសាទ (តោន) | ε% | ផលនេសាទ (តោន) | ε% | |
| ផ្ទេរ | - | | - | | - | | - |
| ទំនាបលិចទឹក | ១១.៨៥៨ | ៤៧,០% | ៤៩៩៦ | ១៤,៦% | ៥,៤៩៩ | ១៣,៩% | ២៤,៦% |
| ភ្នំ | | | ៩៧ | ៣១,៦% | ៩៦០ | ២៩,៤% | ១,២% |
| ខ្ពង់រាប | ១.៧៩៨ | ១៩,០% | ២២០៥ | ១៣,៧% | ២១៨៧ | ៣០,២% | ៦,៨% |
| ទន្លេសាប | ២៧.៥០៣ | ៤០,៨% | ១៣.២៧៦ | ១៩,៨% | ២០.៥៣៥ | ១១,៨% | ៦៧,៤% |
| **សរុប** | **៤១.១៥៩** | | **២០.៥៧៤** | | **២៩.១៨១** | | |

ε% ជា relative standard error

ក្នុងអំឡុងខែសីហា និងខែកញ្ញា ទំហំសំណាកគោលដៅបានគ្របដណ្ដប់តិចជាង ៥០% មានន័យថា ទិន្នន័យ ដែលអាចប្រើប្រាស់បាន មិនទាន់តំណាងឱ្យការនេសាទទាំងមូលនៅឡើយ។ លើសពីនេះ តំបន់ទំនាបលិចទឹក និងតំបន់ភ្នំ បង្ហាញពីកម្រិតទាបនៃសមាមាត្រគ្រួសារអ្នកនេសាទសកម្ម ដែលតម្រូវអោយ



ធ្វើការបង្កើនទំហំសំណាកនៅតំបន់ទាំងនេះបន្ថែមទៀត។ រហូតទាល់តែការប៉ាន់ប្រមាណផលនេសាទនេះ (CAS) ត្រូវគេអនុវត្តបានរយៈពេលពេញ ១២ខែ ទើបអាចធ្វើការបញ្ជាក់ច្បាស់អំពីការកែតម្រូវលើទំហំសំណាកដែលតម្រូវចាំបាច់ (ដែលការកែប្រែសំណាកអាចទាក់ទងទៅនឹងការប្រែប្រួលទាំងឡាយតាមរដូវទៅតាមកម្រិតគ្រប់ដណ្តប់ និងតាមក្រុមនៃប្រភេទសំណាក)។ បម្រែបម្រួលនៃផលនេសាទនឹងមានភាពផ្សេងគ្នារវាងខែនិងតំបន់នេសាទ ដោយផ្អែកលើលក្ខណៈនៃការនេសាទ ដូចជាប្រតិបត្តិការនៃការនេសាទ (ការប្រើប្រាស់ឧបករណ៍ និងកន្លែងនេសាទ) មានការផ្លាស់ប្តូរ។

សរុបមក ផលនេសាទនៅតំបន់ទន្លេសាបតំណាងឱ្យជិត ៧០% នៃចំនួនផលនេសាទសរុប ហើយតំបន់វាលទំនាបលិចទឹក បានរួមចំណែកផលនេសាទជិតស្មើនឹង ២៥% ផងដែរ។




**ក្រាហ្វិកទី១.** ការចូលរួមចំណែកផលនេសាទ រវាងត្រីនិងវារីសត្វផ្សេងទៀត

ឆ្លងតាមលទ្ធផលនេះ ត្រី គឺនេសាទបានច្រើនជាងវារីសត្វផ្សេងៗទៀត។ ការនេសាទបានវារីសត្វផ្សេងទៀតគឺប្រែប្រួលតាមរដូវកាល ប៉ុន្តែសមាមាត្ររវាងត្រី និងវារីសត្វផ្សេងទៀតនេះ គឺស្របជាមួយនឹងការរកឃើញពីមុនៗរបស់ IFReDI ដោយផ្អែកលើការសិក្សាអំពីការប្រើប្រាស់ផលនេសាទ (consumption studies) ដែល វារីសត្វផ្សេងទៀតតំណាងឱ្យតិចជាង ១០% នៃផលនេសាទទឹកសាបសរុប។

ផលនេសាទតាមប្រភេទ (តារាងទី៤) គឺមានបង្ហាញនូវចំណុចសំខាន់ៗ ចំនួន ៣ ខាងក្រោម៖

- ប្រភេទមិនជាក់លាក់ ការដាក់ជាក្រុមត្រីផ្សេងទៀត ដែលមិនមាននៅក្នុងក្រុមដំរៃ (nei) គឺមានតែ ៦,៦% ប៉ុណ្ណោះ។
- ក្តាម *(Somanniathelpusa brandti)* គឺជាប្រភេទមួយ (វារីសត្វដំរៃទៀត) ដែលនេសាទបានច្រើនជាងគេនៅក្នុងចំណោមប្រភេទដែលនេសាទបានច្រើនជាងគេទាំង២០
- ប្រភេទត្រីសរុបចំនួន ១០៧ប្រភេទ និងក្រុមប្រភេទផ្សេងទៀតត្រូវបានបញ្ចូលនៅក្នុងទិន្នន័យ ដែលក្នុងនោះមានប្រភេទដែលនេសាទបានច្រើនជាងគេទាំង២០ (តំណាងឱ្យ ៧៥% នៃផលនេសាទសរុប) និងត្រី៣ប្រភេទនៅក្នុងផលនេសាទ តំណាងអោយស្មើរតែ ២៧% នៃផលនេសាទ[1]។

[1] ប្រភេទមកពីក្រុម *Henicorhynchus* នៅពេលដែលរួមបញ្ចូលគ្នាឈរលេខរៀងទី៤ តាមទម្ងន់ ឬប្រហែលជា ៧% នៃផលនេសាទសរុប។



ការបង្ហាញនូវលទ្ធផលជាក់លាក់លើប្រភេទត្រីដែលនេសាទបាននេះ គឺផ្អែកទាំងស្រុងលើឈ្មោះហៅតាមតំបន់ជាភាសាខ្មែរ។ មានតែការនេសាទនៅតាមតំបន់វាលទំនាបលិចទឹក ខ្លង់រាប និងទន្លេសាប ប៉ុណ្ណោះដែលមានទិន្នន័យតំណាងគ្រប់គ្រាន់ក្នុងកំឡុងខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២១ ហើយទិន្នន័យនេះនឹងមិនមានការប្រែប្រួលខ្លាំងទេបើប្រៀបធៀបគ្នានៅពេលដែលចំនួនសំណាកទាំងអស់ត្រូវបានជ្រើសរើស។ ទោះជាយ៉ាងណាក៏ដោយ ការនេសាទនៅតំបន់ភ្នំ និងឆ្នេរ មិនរំពឹងថានឹងអាចរួមចំណែកលើសពី ៥% នៃផលនេសាទសរុប នោះក៏មិនរំពឹងថានាំឱ្យមានការប៉ះពាល់ខ្លាំងដល់បម្រែបម្រួលទិន្នន័យអំពីការរួមចំណែកតាមប្រភេទទាំងនេះផងដែរ ។

**តារាងទី៤.** ទម្ងន់ផលនេសាទលើប្រភេទចំនួន ២០ ដែលនេសាទបានច្រើនជាងគេ ចាប់ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ ២០២១ និងសមាមាត្រនៃផលនេសាទតាមប្រភេទ និងក្រុមប្រភេទនីមួយៗ

| | ឈ្មោះវិទ្យាសាស្ត្រ | ផលនេសាទ (គ.ក្រ) | ការរួមចំណែកផលនេសាទ | |
|---|---|---|---|---|
| | | | សមាមាត្រ | ការបូកយោង |
| ១ | *Clarias batrachus* | ៥០៨,៣ | ១១,៦% | ១១,៦% |
| ២ | *Anabas testudineus* | ៣៥៦,៤ | ៨,១% | ១៩,៧% |
| ៣ | *Channa striata* | ៣០៣,៩ | ៦,៩% | ២៦,៦% |
| ៤ | *Other fish nei* | ២៩១,១ | ៦,៦% | ៣៣,៣% |
| ៥ | *Oxyeleotris marmorata* | ២២៥,៨ | ៥,១% | ៣៨,៤% |
| ៦ | *Puntioplites proctozysron* | ២០១,៨ | ៤,៦% | ៤៣,០% |
| ៧ | *Mystus mysticetus / Mystus bocourti* | ១៥៧,៣ | ៣,៦% | ៤៦,៦% |
| ៨ | *Labiobarbus siamensis* | ១៥១,៨ | ៣,៥% | ៥០,០% |
| ៩ | *Henicorhynchus siamensis* | ១២៦,៦ | ២,៩% | ៥២,៩% |
| ១០ | *Cyclocheilichthys repasson* | ១២៤,០ | ២,៨% | ៥៥,៨% |
| ១១ | *Somanniathelpusa brandti* | ១១២,៥ | ២,៦% | ៥៨,៣% |
| ១២ | *Henicorhynchus lobatus* | ១១២,១ | ២,៦% | ៦០,៩% |
| ១៣ | *Trichopodus microlepis* | ៨៧,៩ | ២,០% | ៦២,៩% |
| ១៤ | *Hemibagrus spilopterus* | ៨៥,៧ | ២,០% | ៦៤,៨% |
| ១៥ | *Puntioplites falcifer* | ៨២,៩ | ១,៩% | ៦៦,៧% |
| ១៦ | *Cyclocheilichthys enoplos* | ៧៩,៦ | ១,៨% | ៦៨,៥% |
| ១៧ | *Paralaubuca typus* | ៧៩,១ | ១,៨% | ៧០,៣% |
| ១៨ | *Henicorhynchus sp.* | ៦៨,០ | ១,៥% | ៧១,៩% |
| ១៩ | *Barbonymus gonionotus* | ៦៧,៤ | ១,៥% | ៧៣,៤% |
| ២០ | ប្រភេទផ្សេងទៀត | ១១៦៦,៦ | ២៦,៦% | ១០០,០% |



ភាពចម្រុះនៃប្រភេទដែលនេសាទបានច្រើនជាងគេបំផុត គឺនៅខែសីហា សម្រាប់រយៈពេល ៣ខែ ទាំងតំបន់ខ្ពង់រាប និងទន្លេសាប មានចំនួនប្រហាក់ប្រហែលគ្នា។ ដោយសារ តំបន់នេសាទទាំងអស់មិនទាន់គ្រប់ដណ្ដប់ពេញលេញ ហើយទិន្នន័យប្រមូលបានមានត្រឹមតែ៣ខែដំបូងនោះ គឺមិនអាចធ្វើការប្រៀបធៀបលម្អិតរវាងខែ និងខែ ឬរវាងការរួមចំណែកតាមក្រុមនៃប្រភេទចំបងៗ[2] បានឡើយ។

**តារាងទី៥.** ចំនួននៃប្រភេទ ដែលនេសាទបានតាមខែ និងតាមតំបន់នេសាទ

| តំបន់នេសាទ | កក្កដា | សីហា | កញ្ញា | ប្រភេទដែលមានលក្ខណៈពិសេសផ្សេងពីគេ |
|---|---|---|---|---|
| ឆ្នេរ | | | | |
| ទំនាបលិចទឹក | ២៣ | ៣៨ | ៣៦ | **៥៦** |
| ភ្នំ | | ៥ | ៤ | **៨** |
| ខ្ពង់រាប | ៣៥ | ៧៥ | ៤០ | **៨៦** |
| ទន្លេសាប | ៥១ | ៤៩ | ៥៧ | **៧៨** |
| **ប្រភេទដែលមានលក្ខណៈពិសេសផ្សេងពីគេ** | **៦៩** | **៩២** | **៨០** | **១០៧** |

**តារាងទី៦.** តម្លៃលើប្រភេទចំនួន ២០ ដែលនេសាទបានច្រើនជាងគេ (១០០០ រៀល) និងសមាមាត្រនៃតម្លៃតាមប្រភេទ និងក្រុមប្រភេទនីមួយៗ

| | ឈ្មោះវិទ្យាសាស្ត្រ | តម្លៃ (១០០០រៀល) | ការរួមចំណែកនៃតម្លៃ | |
|---|---|---|---|---|
| | | | សមាមាត្រ | ការបូកយោង |
| ១ | *Clarias batrachus* | ៤១៩៥,៩ | ១៤,២% | ១៤,២% |
| ២ | *Channa striata* | ៣៦៤៦,៨ | ១២,៤% | ២៦,៦% |
| ៣ | *Anabas testudineus* | ២៨៦៤,៩ | ៩,៧% | ៣៦,៣% |
| ៤ | *Other fish nei* | ២៥៤២,៧ | ៨,៦% | ៤៥,០% |
| ៥ | *Mystus mysticetus / Mystus bocourti* | ១៤៣៤,៦ | ៤,៩% | ៤៩,៨% |
| ៦ | *Puntioplites proctozysron* | ១២៩៧,៥ | ៤,៤% | ៥៤,២% |
| ៧ | *Oxyeleotris marmorata* | ១២៧៨,៥ | ៤,៣% | ៥៨,៦% |
| ៨ | *Labiobarbus siamensis* | ១០០៥,៦ | ៣,៤% | ៦២,០% |
| ៩ | *Henicorhynchus siamensis* | ៩៧៨,៩ | ៣,៣% | ៦៥,៣% |
| ១០ | *Hemibagrus spilopterus* | ៩១០,០ | ៣,១% | ៦៨,៤% |
| ១១ | *Cyclocheilichthys repasson* | ៨៥៧,០ | ២,៩% | ៧១,៣% |
| ១២ | *Cyclocheilichthys enoplos* | ៨១៥,៥ | ២,៨% | ៧៤,១% |
| ១៣ | *Henicorhynchus lobatus* | ៧៣៧,៧ | ២,៥% | ៧៦,៦% |

[2] សំដៅលើត្រីស ត្រីខ្មៅ និងត្រីប្រផេះ ដែលគេដាក់ឈ្មោះតាមលក្ខណៈជីវសាស្ត្រនៃការធ្វើចរាចរ និងជម្រកសំខាន់ៗ ដែលគេអាចសង្កេតឃើញប្រភេទទាំងនេះ



| | | | | |
|---|---|---|---|---|
| ១៤ | *Puntioplites falcifer* | ៧១៨,៨ | ២,៤% | ៧៩,០% |
| ១៥ | *Paralaubuca typus* | ៦៥៧,៦ | ២,២% | ៨១,២% |
| ១៦ | *Henicorhynchus sp.* | ៦២៧,៤ | ២,១% | ៨៣,៤% |
| ១៧ | *Gourami Trichopodus microlepis* | ៦១៥,៤ | ២,១% | ៨៥,៤% |
| ១៨ | *Barbonymus gonionotus* | ៥៧៣,៤ | ១,៩% | ៨៧,៤% |
| ១៩ | *Pangasius macronema* | ៤៦៧,៣ | ១,៦% | ៨៩,០% |
| ២០ | ប្រភេទផ្សេងទៀត | ៣២៤៩,២ | ១១,០% | ១០០,០% |

ឆ្លងតាមលទ្ធផលនេះ (តារាងទី៦) បង្ហាញថា ទោះបីមានប្រភេទខ្លះមានតម្លៃខ្ពស់ ប៉ុន្តែជារួមតម្លៃរវាងប្រភេទនីមួយៗមានការប្រែប្រួលតិចតួច នេះគឺដោយសារប្រភេទចំនួន១០ខាងលើគេ គឺស្ទើរតែដូចគ្នាទៅនឹងផលនេសាទគិតជាទម្ងន់ ដែលមានបង្ហាញក្នុងតារាងទី៤។ ។ ប្រភេទទាំង ២០នេះ គឺតំណាងអោយច្រើនជាង ៩០% នៃតម្លៃសរុប និងជាប្រភេទដែលមានសារៈសំខាន់ខាងសេដ្ឋកិច្ចខ្ពស់ផងដែរ។




**ក្រាហ្វិកទី២.** ការប្រើប្រាស់ផលនេសាទ (បញ្ចូលគ្នាគ្រប់តំបន់នេសាទទាំងអស់)

លទ្ធផលបង្ហាញថា (ក្រាហ្វិកទី២) ភាគច្រើន គឺគ្រួសារអ្នកនេសាទបានយកទៅលក់[3]។ ការប៉ាន់ប្រមាណនេះហាក់មិនត្រូវគ្នាទៅនឹងភាពជាក់ស្តែងនៃការប្រកបរបរជួញដូរត្រីនៅតំបន់ទន្លេសាប ដោយស្ទើតែ ៨០% នៃផលនេសាទនៅតំបន់ទន្លេសាបបានត្រូវបានគេយកទៅលក់។ ដូចមានបង្ហាញ (តារាងទី៧) ការជួញដូរត្រីមិនសូវសំខាន់សម្រាប់តំបន់វាលទំនាបលិចទឹក និងខ្ពង់រាបនោះទេ នេះគឺដោយហេតុថា ផលនេសាទប្រមាណជា ៣៥%-៥០% នៅតាមតំបន់នេសាទនេះ ត្រូវបានគេលក់ ហើយការប្រើប្រាស់ក្នុងគ្រួសារប្រមាណជា ៤២-៤៨% នៃផលនេសាទសរុបនៅតាមតំបន់នេសាទទាំងពីរនេះផងដែរ។ ផលនេសាទផ្សេងទៀតត្រូវបានគេប្រើជាចម្បងសម្រាប់ការកែច្នៃ ហើយក៏មានការប្រើប្រាស់មួយចំនួននៅក្នុងវារីវប្បកម្ម ឬសម្រាប់ការចិញ្ចឹមសត្វតាមគ្រួសារ។

**តារាងទី៧.** ការប្រើប្រាស់ផលនេសាទតាមតំបន់នេសាទ

| | **តំបន់វាលទំនាបលិចទឹក** | **តំបន់ខ្ពង់រាប** | **តំបន់ទន្លេសាប** |
|---|---|---|---|
| លក់ | ៥០,០% | ៣៤,៦% | ៧៨,៥% |

[3] ចំនុចនេះគឺផ្អែកលើទម្ងន់ស្តង់ដារ ដែលបានគណនាសម្រាប់ផ្នែកនៃការប្រើប្រាស់ត្រី ដោយផ្អែកលើសារៈសំខាន់នៃផលនេសាទសរុបតាមតំបន់នេសាទ។



| | | | |
|---|---|---|---|
| ប្រើប្រាស់ក្នុងគ្រួសារ | ៤២,០% | ៤៨,២% | ១៩,៧% |
| ផ្សេងទៀត | ៨,០% | ១៧,២% | ១,៨% |

គ្រួសារអ្នកនេសាទភាគច្រើនបានប្រើប្រាស់ទូកជាមធ្យោបាយក្នុងការទៅនេសាទត្រី (ក្រាហ្វិកទី៣) ដែលក្នុងនោះជាងពាក់កណ្ដាល គឺប្រើទូកប្រើម៉ាស៊ីន ហើយ ១៤% ប្រើទូកដោយមិនមានម៉ាស៊ីន។ ចំពោះផលនេសាទបានមកមិនប្រើទូក ពោលគឺការនេសាទនៅជិតកន្លែងដែលគ្រួសារអ្នកនេសាទរស់នៅ គឺមានប្រមាណជា៣៥% នៃផលនេសាទសរុប ។




ក្រាហ្វិកទី៣. សមាមាត្រនៃការប្រើប្រាស់ទូក និងមិនប្រើប្រាស់ទូកជាមធ្យោបាយរួមផ្សំសម្រាប់ធ្វើនេសាទ (បញ្ចូលគ្នាគ្រប់តំបន់នេសាទទាំងអស់)

**តារាងទី៨.** សមាមាត្រនៃការប្រើប្រាស់ទូក និងមិនប្រើប្រាស់ទូកជាមធ្យោបាយរួមផ្សំសម្រាប់ធ្វើនេសាទតាមតំបន់នេសាទ

| | តំបន់វាលទំនាបលិចទឹក | តំបន់ខ្ពង់រាប | តំបន់ទន្លេសាប |
|---|---|---|---|
| មិនប្រើទូក | ៣៩,៦% | ២១,៤% | ៣៥,២% |
| ប្រើទូកម៉ាស៊ីន | ២៧,៣% | ៤៩,៩% | ៥៣,៩% |
| ប្រើទូកគ្មានម៉ាស៊ីន | ៣៣,០% | ២៨,៧% | ១០,៩% |

ផលនេសាទបានមកដោយប្រើទូកមានម៉ាស៊ីន ភាគច្រើនមាននៅតំបន់ទន្លេសាបនិងតំបន់ខ្ពង់រាប (តារាងទី៨)និងការនេសាទដោយមិនប្រើទូកឬប្រើទូកមិនមានម៉ាស៊ីន គឺភាគច្រើនមាននៅតំបន់ទំនាបលិចទឹក។

ថ្ងៃអង្គារ ៣ រោច ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០២២
ហត្ថលេខា

**បណ្ឌិត ហោង គង់**

**បានឃើញ**
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល និងជាប្រធានកម្មវិធី CAPFISH-Capture**
ថ្ងៃចន្ទ ២ រោច ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០២២

**ពុំ សុធា**